# សេចក្តីប្រកាសព័ត៌មាន

## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

លេខ: ២១ PR-១៧/EoJ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៧

### ជំនួយរបស់ជប៉ុនសំរាប់
### អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៧ រដ្ឋាភិបាលជប៉ុនបានបញ្ចេញប្រាក់ចំនួន **១.២២១.៨១៨ ( មួយលានពីរសែនពីរម៉ឺនមួយពាន់ប្រាំបីរយដប់ប្រាំបី) ដុល្លារអាមេរិក** ជាវិភាគទានសំរាប់ឆ្នាំសារពើពន្ធ ២០១៧ របស់ខ្លួន ដើម្បីផ្តល់ជូនភាគីអង្គការសហប្រជាជាតិ នៃថវិកាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបានសំរេចចិត្តផ្តល់វិភាគទាននេះ ដើម្បីបន្តទ្រទ្រង់ដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ ប្រទេសជប៉ុនកត់សំគាល់នូវការវិវឌ្ឍកាលពីពេលថ្មីៗនេះនៃ អ.វ.ត.ក ដូចជាការធ្វើសវនាការស្តាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង និងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/០១ ហើយទន្ទឹមនឹងនេះលើកទឹកចិត្តឱ្យ អ.វ.ត.ក បន្តដំណើរការលើសំណុំរឿងដែលនៅសេសសល់ក្នុងរបៀបមួយមានភាពត្រឹមត្រូវ មានប្រសិទ្ធភាព និងឆាប់រហ័ស ដោយហេតុថា ជនជាប់ចោទមានវ័យកាន់តែចាស់ជរា និងសុខភាពទន់ខ្សោយ និងដើម្បីសំរេចបាននូវយុត្តិធម៌ដែលកំពុងត្រូវបានទន្ទឹងរង់ចាំអស់រយៈពេលយ៉ាងយូរមកហើយសំរាប់ប្រជាជនកម្ពុជា ។

រដ្ឋាភិបាលជប៉ុនផ្តល់សារៈសំខាន់ទៅលើសាលាក្តីខ្មែរក្រហម ដោយផ្អែកលើទស្សនៈចំនួនបី ។ ទីមួយ ការកាត់ក្តីខ្មែរក្រហមគឺជាដំណាក់កាលបញ្ចប់នៃដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា ដើម្បីបង្ការទប់ស្កាត់ការកើតមានឡើងវិញនៃអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ទីពីរ សាលាក្តីខ្មែរក្រហមនេះនឹងជួយស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ដែលប្រការនេះ នឹងរួមចំណែកដល់ការផ្សះផ្សាជាតិឡើងវិញ ។ ទីបី សាលាក្តីនេះនឹងរួមចំណែកដល់ការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងជួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាំងពីដើមដំបូងរៀងមកហើយគិតត្រឹមថ្ងៃនេះ ជំនួយហិរញ្ញវត្ថុពីប្រទេសជប៉ុនសំរាប់តុលាការនេះ មានចំនួន ៨៦,៣៤ លានដុល្លាអាមេរិក ដោយគិតរួមទាំងការបញ្ចេញថវិកាលើកនេះ ប្រហាក់ប្រហែលនឹង ៣១% នៃថវិកាសរុបដែលផ្តល់ដោយប្រទេសផ្តល់ជំនួយជូនភាគីជាតិ និងភាគីអង្គការសហប្រជាជាតិនៃ អ.វ.ត.ក ។ លើសពីនេះទៅទៀត ប្រទេសជប៉ុនរួមជាមួយប្រទេសបារាំងក្នុងឋានៈជាសហប្រធាននៃមិត្តរបស់ អ.វ.ត.ក. បានតាមដានដំណើរការរបស់តុលាការនេះយ៉ាងសកម្ម ។

---

ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ ១៩៤ មហាវិថីព្រះនរោត្តម ទូរសព្ទ័ : (០២៣) ២១៧ ១៦១/៤ ទូរសារ : ០២៣-២១៦ ១៦២
អ៊ីម៉ែល: political.jpn@pp.mofa.go.jp វេបសាយផ្លូវការ : www.kh.emb-japan.go.jp